**នរោត្តម សីហនុ**
**នៃកម្ពុជា**

ជូន ឯកឧត្តម គាត ឈន់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំបានទទួលហើយលិខិតថ្វាយពរដែលមានអត្ថន័យដ៏ជ្រាលជ្រៅ របស់ឯកឧត្តមនៅក្នុងឱកាសពិធីបុណ្យចំរើនជន្មាយុខ្ញុំ និងខួប២០ឆ្នាំនៃការនិវត្តន៍មកកាន់មាតុប្រទេសនៃខ្ញុំ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះយុត្តិធម៌ដែលឯកឧត្តមផ្តល់ដល់ខ្ញុំ ក្នុងការបំរើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។ នៅក្នុងឱកាសដ៏ល្អប្រសើរនេះ ខ្ញុំសូមសរសើរដ៏កក់ក្តៅជាទីបំផុតឯកឧត្ត ដែលមានឧត្តមគតិស្នេហាជាតិឥតងាករេ ជារៀងដរាបមក ហើយបំពេញភារកិច្ចដើម្បីឧត្តមប្រយោជន៍ប្រជាជាតិ ប្រជារាស្ត្រកម្ពុជា ទទួលបានជោគជ័យច្រើនណាស់។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម និងលោកជំទាវ ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ។

នរោត្តម សីហនុ

ភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១